ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សាកលវិទ្យាល័យ អង្គរខេមរា

# ANGKOR KHEMARA UNIVERSITY

## មហាវិទ្យាល័យ

## សិល្បៈ មនុស្សសាស្ត្រ និងភាសា

## ឯកទេស៖ អក្សរសាស្ត្រខ្មែរ

## មុខវិជ្ជា ៖ អក្សរសិល្ប៍សម័យមុនអង្គរ-អង្គរ

## ប្រធានបទ

## វិភាគបញ្ហាក្នុងរឿងរាមកេរ្តិ៍ខ្មែរ គ្រង់ខ្សែទី៧៩


**បង្រៀននិងណែនាំដោយ៖ បណ្ឌិត ឃិន យ៉ង់**

**រៀបរៀងដោយ និស្សិត ឌី ជីវ័ន្ត**

**និស្សិតអក្សរសាស្ត្រខ្មែរ ជំនាន់ទី១៤ វគ្គទី០១ ឆមាសទី០២ ឆ្នាំទី០៣**

**សាខាពោធិ៍សាត់**


*អត្តលេខ ៖ #AKU01-B-00155 PS*

ព.ស២៥៦៧ ឆ្នាំសិក្សា២០២៣-២០២៤ គ.ស ២០២៤

# ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនចំពោះ៖

- វិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់រូបដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារជាតិមាតុភូមិ។
- វិញ្ញាណក្ខន្ធកវី បណ្ឌិត អ្នកនិពន្ធ អ្នកប្រាជ្ញខ្មែរគ្រប់ជំនាន់។ ដែលបានខិតខំថែរក្សាអក្សរសាស្ត្រជាតិឱ្យរីកចម្រើនគង់វង្សរហូតមកដល់សព្វថ្ងៃ។
- វិញ្ញាណក្ខន្ធសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលព្រះអង្គបាន បន្សល់ស្នាដៃដ៏វិសេសវិសាលសម្រាប់កូនខ្មែរគ្រប់ជំនាន់នោះគឺ សៀវភៅវចនានុក្រមខ្មែរ។
- វិញ្ញាណក្ខន្ធនៃបុព្វការីជនរបស់ខ្ញុំទាំងអស់។

សូមជួយទ្រទ្រង់វិស័យអក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ចនិរន្តរ៍។

# សេចក្តីថ្លែងអំណរគុណ

ទន្ទឹមនឹងការកកើតនូវស្នាដៃឡើងបានជាលទ្ធផលនេះខ្ញុំបាទសូមសម្តែងនូវអំណរគុណជាអនេកប្រការចំពោះ ៖

លោកឪពុក អ្នកម្តាយនៃខ្ញុំទាំងឡាយជាបុព្វាចារ្យនឹងជាព្រះអរហន្តដ៏ប្រសើររបស់ខ្ញុំបាទដែលលោកបានផ្តល់នៅកំណើត ហើយចិញ្ចឹមបីបាច់ថែរក្សាដោយព្រហ្មវិហារធម៌។ ជានិច្ចកាលលោកតែងតែណែនាំ ចង់ឲ្យក្លាយជាគ្រាប់ពូជដ៏មានតម្លៃមួយ។

លោកគ្រូ អ្នកគ្រូទាំងអស់តាំងពីថ្នាក់បឋមសិក្សារហូតមកដែលអស់លោកបានបង្ហាត់បង្រៀនឲ្យខ្ញុំបាទនៅទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបានពោលគឺចំណេះវិជ្ជា ព្រមទាំងសីលធម៌ សុជីវធម៌ក្នុងសង្គមធ្វើឲ្យ ក្លាយជាធនធានដ៏មានតម្លៃមួយសម្រាប់សង្គមជាតិ។

បណ្ឌិត **នូ ចាន់សុភី** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអង្គរខេមរា និងគណៈគ្រប់គ្រងនៃសាកលវិទ្យាល័យអង្គរខេមរាទាំងអស់ធ្វើឲ្យខ្ញុំបានទទួលបានចំណេះដឹងដ៏មានតម្លៃសម្រាប់ជួយខ្លួនឯង គ្រួសារ និងសង្គមជាតិបានមួយចំណែក។

សាស្ត្រាចារ្យក្នុងដេប៉ាតឺម៉ង់ អក្សរសាស្ត្រខ្មែរនៃសាកលវិទ្យាល័យអង្គរខេមរាទាំងអស់ដែលបានខិតខំប្រិតប្រៀនតម្រែតម្រង់នៅមុខវិជ្ជាទាំងឡាយក្នុងជំនាញអក្សរសាស្ត្រខ្មែរញ៉ាំងឲ្យខ្ញុំបាទទទួលនូវចំណេះដឹងយ៉ាងស្រួចស្រាល់លើជំនាញរបស់ខ្ញុំ។ជាពិសេសសូមអរគុណជាអនេក ចំពោះសាស្ត្រាចារ្យបណ្ឌិត **ឃិន យ៉ន** ដែលបង្រៀនលើមុខវិជ្ជាអក្សរសិល្ប៍សម័យមុនអង្គរ-អង្គរដែលបានណែនាំ កែតម្រូវលើការស្រាវជ្រាវមួយនេះ។

# មាតិកា

**I ជំពូកទី១៖ សេចក្ដីផ្ដើម** ........................................ ទំព័រទី១-៣

១.១ ប្រវត្តិបញ្ហា ........................................

១.២ ចំណោទបញ្ហា ........................................

១.៣ គោលបំណងនាំការស្រាវជ្រាវ ........................................

១.៤ ដែនកំណត់ ........................................

១.៥ វិធីសាស្ត្រស្រាវជ្រាវ ........................................

១.៦ សារប្រយោជន៍នៃការស្រាវជ្រាវ ........................................

១.៧ រចនាសម្ព័ននៃការស្រាវជ្រាវ ........................................

**II ជំពូកទី២៖ អំពីរឿងរាមកេរ្តិ៍** ........................................ ទំព័រទី៣-៤

២.២ ប្រវត្តិ ........................................

២.៣ អ្នកនិពន្ធ ........................................

**III ជំពូកទី៣៖ ការវិភាគអត្ថន័យ អត្ថរូប អត្ថរស** ........................................ ទំព័រទី៤-១១

**៣.១ វិភាគអត្ថន័យ**

៣.១.១ សង្ខេបរឿង ........................................

៣.១.២ ប្រធានរឿង ........................................

៣.១.៣ មូលបញ្ហារឿង ........................................

៣.១.៤ វិភាគបញ្ហាទំនាស់ និងដំណោះស្រាយ ........................................

៣.១.៥ វិភាគតួអង្គ ........................................

៣.១.៥ វិភាគបញ្ហាផ្សេងៗ ........................................

**៣.២ វិភាគអត្ថរូប**

៣.២.១ វិភាគពាក្យពេចន៍ ........................................

៣.២.២ វិភាគឃ្លាល្បះ ........................................................................

៣.២.៣ វិភាគជើងកាព្យ......................................................................

**៣.៣ វិភាគអត្ថរស**

៣.៣.១ វិភាគអច្ឆរិយរស ...................................................................

៣.៣.២ វិភាគកុសលរស.....................................................................

៣.៣.៣ វិភាគទារុណរស ....................................................................

៣.៣.៤ វិភាគហាសរស .......................................................................

**IV ជំពូកទី៤៖ លក្ខណៈវិជ្ជមាន អវិជ្ជមាន** (ឥទ្ធិពល តម្លៃសង្គម ការអប់រំ...) ........................ ទំព័រទី១១

៤.១ លក្ខណៈវិជ្ជមាន..........................................................................

៤.២ លក្ខណៈអវិជ្ជមាន.......................................................................

**V ជំពូកទី៥៖ សន្និដ្ឋាន** .................................................................................. ទំព័រទី១១

ឯកសារពិគ្រោះ ...............................................................................

# I ជំពូកទី១៖ សេចក្ដីផ្ដើម

## ១.១ ប្រវត្តិបញ្ហា

ស្នាដៃអក្សរសិល្ប៍ខ្មែរបានផ្លាស់ប្ដូរទៅលើអត្ថន័យ អត្ថរូប ស្របទៅតាមសម័យកាលនៃប្រវត្តិសាស្ត្រ ហូតដល់ មានការបែងចែកអក្សរសិល្ប៍ជាបីស័យកាលគឺ អក្សរសិល្ប៍សម័យបុរាណ អក្សរសិល្ប៍សម័យកណ្ដាល និងអក្សរសិល្ប៍សម័យទំនើប។

ដោយផ្អែកលើទ្រឹស្ដីនៃការសិក្សាលើមុខវិជ្ជាអក្សរសិល្ប៍បុរាណ បានកំណត់ថាស្នាដៃដែលមានការ ឯកភាពលើអត្ថន័យ អត្ថរូប និងអត្ថរសនោះជាស្នាដៃលមានលក្ខណៈតន្តី។ ក្រោយពីបានសិក្សាស្នាដៃរួចមក យើងឃើញថា រឿងរាមកេរ្តិ៍ គឺជាអក្សរសិល្ប៍បែបព្រាហ្មណ៍និយមខ្មែរដែលមានអត្ថន័យ អត្ថរូប និងអត្ថរស ប្រកបដោយលក្ខណៈល្អវិសេសវិសាល។ អ្នកនិពន្ធបានតាក់តែងជាកាព្យដែលទទួលបានការចាប់អារម្មណ៍ពេញចិត្តជាខ្លាំងពីមហាជននៅសម័យនោះ។ ទៀតសោតស្នាដៃនេះបានបង្កប់នូវតម្លៃជាច្រើន ដែលមានតាំងពីរបបគ្រប់គ្រង នយោបាយ ទំនៀមទម្លាប់ ជីវភាពរសនោះ ស្ថានភាពរបស់សង្គម ស្ថានភាពគ្រួសារជាដើម។ តម្លៃទាំងនេះបានផ្ទុកទៅដោយឧត្ដមគតិ ដំបូន្មាន គំនិតល្អៗ។ ដូចនេះហើយទើបខ្ញុំបាទ សម្រេចយកស្នាដៃរឿងរាមកេរ្តិ៍ខ្មែរក្នុងអក្សរសិល្ប៍ព្រាហ្មណ៍និយម មកសិក្សាវិភាគ ក្នុងខ្សែទី៧៩ដែលកំណត់ប្រធានបទថា "វិភាគបញ្ហាក្នុងរឿងរាមកេរ្តិ៍ខ្មែរ ត្រង់ខ្សែទី៧៩" ។

## ១.២ ចំណោទបញ្ហា

រឿងរាមកេរ្តិ៍ខ្មែរ គឺជាប្រភេទអក្សរសិល្ប៍បុរាណ ដែលការតាក់តែងឡើងឡើងប្រកបទៅដោយសិល្បវិធីយ៉ាងល្អឯក។ រឿងរាមកេរ្តិ៍ចខ្មែរបានបង្ហាញពីតួអង្គព្រះរាមជា អាវតាផងនិងជាមនុស្សផង។ ដូចនេះហើយការយករឿងរាមកេរ្តិ៍មកសិក្សា ដើម្បីស្វែងឱ្យឃើញពីលក្ខណៈពិសេសនៅក្នុងរឿងរាមកេរ្តិ៍៖

-តើសកម្មភាពបែបណាខ្លះដែលថាព្រះរាមជា អាទិទេព្វ និងជាមនុស្ស?

-តើអក្សរសិល្ប៍បុរាណបានផ្ដល់នូវតម្លៃយ៉ាងណាខ្លះ ចំពោះអ្នកសិក្សា និងសង្គម?

-តើរឿងរាមកេរ្តិ៍ខ្មែរបានផ្ដល់គំនិតអប់រំអ្វីខ្លះ ដល់មហាជន?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការជ្រើសរើសយកប្រធានបទ "វិភាគបញ្ហាក្នុងរឿងរាមកេរ្តិ៍ខ្មែរ ត្រង់ខ្សែទី៧៩" មកធ្វើការសិក្សា ស្រាវជ្រាវនេះគឺក្នុងគោលបំណង

- ទទួលបានចំណេះដឹងសំខាន់ៗ ពីការសិក្សាលក្ខណៈតន្តីក្នុងស្នាដៃ
- ដើម្បីបន្សល់ទុកជាមេរៀនឬ ជាឯកសារនៃការវិភាគបញ្ហាក្នុងរឿងរាមកេរ្តិ៍ខ្មែរ ក្នុងវគ្គទី៧៩ សម្រាប់អ្នកសិក្សាជំនាន់ក្រោយ

- លើកកម្ពស់ដល់ការសិក្សាស្រាវជ្រាវ លើវិស័យអក្សរសិល្ប៍ខ្មែរឱ្យកាន់តែរីកចម្រើន
- ចូលរួមលើកតម្លៃនៃស្នាដៃតែងនិពន្ធ របស់អ្នកនិពន្ធខ្មែរជំនាន់មុនៗ។

## ១.៤ ដែនកំណត់

ក្នុងការសិក្សានេះ ដោយផ្អែកទៅលើអក្សរសិល្ប៍ព្រាហ្មណ៍និយម ឬអក្សរសិល្ប៍តន្តីខ្មែរ សម្រាប់លើយកមកធ្វើការវិភាគឱ្យឃើញនូវបញ្ហាផ្សេងៗដែលកើតមានឡើងក្នុងខ្សែទី៧៩នៃរឿងរាមកេរ្តិ៍មកធ្វើការចោទនិងស្រាយ។

## ១.៥ វិធីសាស្ត្រស្រាវជ្រាវ

ជាការពិតណាស់នៅក្នុងការស្រាវជ្រាវមួយនេះ គឺធ្វើឡើងទៅតាមវិធីនៃការសិក្សាវិភាគរែកញែករកនូវបញ្ហាផ្សេងៗរបស់សាច់រឿងត្រង់ខ្សែទី៧៩ដើម្បីវិភាគរកហេតុផលនៃបញ្ហា។

## ១.៦ សារប្រយោជន៍នៃការស្រាវជ្រាវ

ចំពោះការសិក្សារឿងនៅក្នុងខ្សែទី៧៩ គឺជាការសិក្សាដើម្បីពង្រឹងនូវចំណេះដឹងបន្ថែម ទៅលើស្នាដៃបុរាណ និងរក្សាស្នាដៃដែលជាកេរដំណែលរបស់ខ្មែរយើង បានបន្សល់ទុកតាំងពីបុរាណ ព្រមទាំងបានបន្សល់ទុកស្នាដៃឱ្យអ្នកសិក្សាជំនាន់ក្រោយបានយល់ បានដឹង និងបានស្គាល់ ព្រមទាំងទុកឱ្យអ្នកសិក្សាជំនាន់ក្រោយទុកជាឯកសារប្រើប្រាស់ទៅតាមតម្រូវការរបស់។ ក្នុងការសិក្សាស្រាវជ្រាវនេះ ខ្ញុំបាទសង្ឃឹមថានៅពេលដែលស្រាវជ្រាវបានបញ្ចប់ដោយជោគជ័យកិច្ចការស្រាវជ្រាវនេះនឹងផ្តល់ជាសារៈប្រយោជន៍ជាច្រើនចំពោះសង្គមខ្មែរ ដូចជា៖

- ផ្តល់ជាចំណេះដល់អ្នកអានពីបញ្ញត្តិ ទ្រឹស្តីផ្សេងៗ ដែលទាក់ទងនឹងលក្ខណៈរបស់អក្សរសិល្ប៍បុរាណ
- បានជាចំណេះដឹងសំខាន់ៗ ពីការសិក្សាវិភាគបញ្ហាក្នុងស្នាដៃ
- រួមចំណែកក្នុងការកសាងធនធានឯសារ ដែលទាក់ទងទៅនឹងអក្សរសិល្ប៍តន្តី
- ចូលរួមការពារនូវអត្តសញ្ញាណជាតិ ដោយបានលើស្ទួយលើវិស័យអក្សរសិល្ប៍ដែលបានផ្តល់ជាឧត្តមគតិ ក្នុងសង្គមរបស់ខ្មែរ ជាពិសេសនោះទុកជាមូលដ្ឋាន សម្រាប់អ្នកសិក្សាជំនាន់ក្រោយឱ្យយល់ច្បាស់ថា ជាតិខ្មែរមានអក្សរសិល្ប៍ដែលបង្កប់នូវគំនិតល្អៗសម្រាប់ផ្តល់ជាគតិអប់រំដល់មនុស្សជំនាន់ក្រោយទៀតផង។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សានេះយើងធ្វើការរៀបចំរចនាសម្ព័ន្ធដូចខាងក្រោម៖

- ជំពូកទី១៖ សេចក្តីផ្តើម ដែលមានប្រវត្តិបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ វិធីសាស្ត្រស្រាវជ្រាវ សារប្រយោជន៍នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

- ជំពូកទី២៖ អំពីរឿងរាមកេរ្តិ៍មាន ប្រវត្តិ អ្នកនិពន្ធ។
- ជំពូកទី៣៖ ការវិភាគអត្ថន័យ(សង្ខេបរឿង ប្រធានរឿង មូលបញ្ហារឿង វិភាគបញ្ហាទំនាស់និងដំណោះស្រាយ វិភាគតួអង្គ វិភាគបញ្ហាផ្សេងៗ) វិភាគអត្ថរូប(វិភាគពាក្យពេចន៍ វិភាគឃ្លាល្បះ វិភាគជើងកាព្យ) វិភាគអត្ថរស(វិភាគអច្ឆរិយរស វិភាគកុសលរស វិភាគទារុណរស វិភាគហាសរស)។
- ជំពូកទី៤៖ លក្ខណៈវិជ្ជមាន អវិជ្ជមាន (ឥទ្ធិពល តម្លៃសង្គម ការអប់រំ...)។
- ជំពូកទី៥៖ សន្និដ្ឋាន និងឯកសារពិគ្រោះ។

# II ជំពូកទី២៖ អំពីរឿងរាមកេរ្តិ៍

## ២.២ ប្រវត្តិ

រឿងរាមកេរ្តិ៍ គឺជាការប្រែសម្រួលនៃរឿងរាមាយណៈ ដែលនិយាយពីច្បាំងមួយយ៉ាងធំក្នុងប្រទេសឥណ្ឌាពីបុរាណ ហើយគេបានចាត់ទុកថាជាស្នាដៃរបស់លោក វាល្មិកិ។ ពាក្យពេចន៍ ដែលបានប្រើក្នុងរឿងនេះជាភាសាបាលីសំស្រ្កឹត ក្នុងរវាង ព.ស.ប្រមាណ៧៥០ឆ្នាំ ហើយក៏ផ្សព្វផ្សាយចេញពីខេត្តមួយទៅខេត្តមួយ។ អ្នកដែលនាំរឿងនេះទៅនិយាយផ្សាយក៏ពោលបន្ថែមបន្ថយ ឬបំពេញតាមអធ្យាស្រ័យរបស់ខ្លួន ដើម្បីឱ្យពីរោះដល់អ្នកស្តាប់។ ជួនកាលទៀត មានយករឿងរ៉ាវដែលមានក្នុងស្រុកផ្សេងៗមកបញ្ចូលជាមួយបន្ថែមទៀតដើម្បីឱ្យបានអ្នកស្រុកកាន់តែចូលចិត្តរឿងនេះថែមទៀត។ ហេតុនេះហើយបានជាភាសាសំស្រ្កឹត ដែលនិទានតៗគ្នាពីមួយទៅមួយបានក្លាយជាការគោរព និងជាអក្សរសាស្រ្តសម្រាប់ស្រុកភូមិនីមួយៗ។

## ២.៣ អ្នកនិពន្ធ

គេពុំអាចរកឃើញឈ្មោះអ្នកនិពន្ធ តែប្រហែលជាអ្នកប្រាជ្ញខ្មែរដែលចេះភាសាសំស្រ្កឹតយ៉ាងច្បាស់លាស់ និងមានទំនោរទៅរកពុទ្ធសាសនា។ ប្រហែលជាមានអ្នកនិពន្ធពីរនាក់គឺ៖

-ពីខ្សែទី១-១០ មានអ្នកនិពន្ធម្នាក់

-ពីខ្សែទី៧៥-៨០ មានអ្នកនិពន្ធម្នាក់ទៀត។ ( *ទស្សនៈលោកញ៉ុកថែម,រឿងរាមកេរ្តិ៍, លាង ហាប់អាន*)

បើពិនិត្យតាមអត្ថន័យរឿងឃើញថា រាមកេរ្តិ៍ខ្មែរអាចតាក់តែងឡើងក្នុងពេលដែលប្រទេសខ្មែរកំពុងតែមានទំនាស់សាសនា គឺក្នុងអំឡុងស.វទី១១ទៅទី១២។

ចំណែកតាមជញ្ជាំងប្រាសាទវិញ គេឃើញមានរូបចម្លាក់មួយចំនួនដែលទាក់ទងទៅនឹងដំណើររឿងរាមកេរ្តិ៍ និងរាមាយណៈមាននៅតាមជញ្ជាំងប្រាសាទដូចជាប្រាសាទកោះកេរ (ដើម ស.វទី១០) ប្រាសាទបន្ទាយស្រី (ពាក់កណ្តាល ស.វទី១០) ប្រាសាទបាពួន (ដើមស.វទី១១) ប្រាសាទអង្គរ (ដើម ស.វទី១២)។ ចំណែកភាសាសរសេរក្នុងឯកសាររឿងរាមកេរ្តិ៍របស់**អ្នកអង្គម្ចាស់**

**វង្សាធាយាវង្ស** ដែលយើងកំពុងសិក្សាសព្វថ្ងៃឃើញថា បទនិពន្ធនេះ សរសេរក្រោយសម័យអង្គរ ជាពិសេសគឺចាប់ពីខ្សែទី៧៥-៨០ជាអត្ថបទងាយអានងាយយល់ ប្រហាក់ប្រហែលនឹងភាសាសរសេរទំនើបដែល។

## III ជំពូកទី៣៖ ការវិភាគអត្ថន័យ អត្ថរូប អត្ថរស

### ៣.១ វិភាគអត្ថន័យ

#### ៣.១.១ សង្ខេបរឿង

នាងសីតាបញ្ឈឺចិត្តព្រះរាម ដោយបញ្ជាក់ថាកាលពីមុនព្រះអង្គដឹងថា នាងស្មោះត្រង់តាមរយៈហនុមានទៅស៊ើបការ និងតាមវិធីលុយភ្លើង ម្ដេចនៅតែព្រះអង្គសម្លាប់នាងទៀត។ ឥឡូវនេះនាងនៅក្នុងព្រះតែងជួបយក្សាជួបព្រានព្រៃផងនោះព្រះអង្គរឹតតែប្រច័ណ្ឌនិងយកទោសនាងខ្លាំងលើសពីមុនទៅទៀត។ ព្រះរាមសុំឱ្យព្រះនាងយកព្រះខ័នមកកាត់កព្រះអង្គចោលបើពុំអាណិតទេ។ ប៉ុន្តែព្រះនាងតបថា "បពិត្រពាក្យនេះពីរោះមធូរស្មានមេត្រី ផ្អែមលើសក្រៃលែង ចំណីធីហើយឈឺពោះមិនខាន"។

ព្រះរាមដឹងថា ពុំអាចយកជ័យជម្នះលើពាក្យសត្យរបស់នាងពុំបាន ក៏រកមធ្យោបានសុំបុត្រដើម្បីឱ្យនាងសីតាទៅតាម ប៉ុន្តែនាងសីតាបញ្ឈឺចិត្តព្រះរាមទៀត។ ព្រះរាមយុះសោកចង់សម្លាប់ខ្លួននៅទីនោះ។ សីតាខ្លាចស្វាមីសោយទិវង្គតមែនក៏ហៅបុត្រមកប្រគល់ឱ្យព្រះរាមនៅពេលនោះទៅ។ ព្រះរាមនាំបុត្រទៅជួបនឹងព្រះអនុជទាំងបីអង្គ ព្រមទាំងហនុមាននិងសេនាទាំងអស់នៅក្រៅអាស្រម។ អ្នកទាំងអស់គ្នាបានសុំទោសទៅវិញទៅមក។

ព្រះរាមបានវិញចូលទៅនគរវិញ ហើយបាននាំបុត្រទាំងពីរទៅថ្វាបង្គំមាតាទាំងបីអង្គ។ ពេលនោះជីដូននិងចៅបានស្គាល់គ្នា និងបានសំណេះសំណាលគ្នាពីរឿងអតីតកាល។ ព្រះរាមបានចាត់សុម័ន្តមន្ត្រីឱ្យជ្រើសរើសរកកុមារីអាយុ១០ឆ្នាំ មានរូបឆោមល្អត្រកូលខ្ពស់មកធ្វើជាភីលៀងរាជមុការទាំងពីរ។ ព្រះរាមបានចាត់ចែងជប់លៀងបុត្រយ៉ាងមហោឡារិក។

យប់មួយព្រះរាជកុមារយំរលឹកមាតា ព្រះរាមក៏រលឹកដែរ ហើយក៏ចូលទៅលួងលោមបុត្រទាំងពីរ។ លុះព្រឹកឡើងព្រះរាមឱ្យសេនានិងភីលៀងដង្ហែកុមារទៅជួបម្ដាយ ប៉ុន្តែមុននឹងចេញដំណើរទៅព្រះអង្គប្រាប់បុត្រឱ្យជួយអង្វរនាងសីតា ព្រមវិលចូលវាំងវិញ បើព្រះនាងមិនព្រមព្រះអង្គនឹងសុគតនៅថ្ងៃណាមួយ ហើយបើនិយាយដូច្នេះហើយ នៅតែមិនព្រមទើបទ្រង់ឱ្យភីលៀងនៅបម្រើនាងនៅទីនោះ។

រាជកុមារ បាននាំភីលៀងទៅជួបមាតាដូចបំណង។ ពេលនោះម្ដាយនិងកូនយំរលឹកគ្នាយ៉ាងខ្លាំង។ ចំណែកឯភីលៀង ដែលធ្លាប់ដង្ហែនាងសីតាទៅក្រសាលទឹកពីមុនមកនោះ ក៏យំរៀបរាប់ដែរ។ សីតាបានបញ្ជាក់ថា នេះជាកម្មរបស់នាងទេ។

#### ៣.១.២ ប្រធានរឿង

តាមរយៈដំណើររឿងក្នុងខ្សែទី៧៩អ្នកនិពន្ធបានបង្ហាញពីសកម្មភាពព្រះរាមលួងលោមនាសីតាពីវិធីមួយទៅវិធីមួយ ដូចនេះប្រធានរឿងស្ថិតនៅក្នុង "ទំនាស់វិបត្តិផ្ទៃក្នុងគ្រួសាររបស់ព្រះរាម"។

## ៣.១.៣ មូលបញ្ហារឿង

វិលជុំវិញបញ្ហានៅត្រង់ខ្សែទី៧៩នេះបានបង្ហាញពីភាពជាមនុស្សរបស់ព្រះរាម ដែលធ្វើឱ្យតម្លៃរឿងរាមកេរ្តិ៍ខ្មែរមានលក្ខណៈមនុស្សសុទ្ធសាធ។

## ៣.១.៤ វិភាគបញ្ហាទំនាស់ និងដំណោះស្រាយ

**-បញ្ហាទំនាស់៖** "ប្រច័ណ្ឌ"

**-គូទំនាស់៖** ព្រះរាម ↔ នាងសីតា

**ទំនាស់រវាងព្រះរាមនិងមហេសី(នាងសីតា)**

ការលែងលះគ្នាបណ្តាលមកពីរឿងប្រច័ណ្ឌខ្លាំងពេកនេះហើយដែលធ្វើឱ្យព្រះរាមលែងស្គាល់ខុសត្រូវពុំទទួលយកការពិតរបស់នាងសីតា។ ទោះបីនាងព្យាយាមពន្យល់យ៉ាងណា ក៏ព្រះរាមនៅតែបញ្ជាឱ្យព្រះលក្ស្មណ៍យកនាងទៅសម្លាប់ចោលទាំងមានផ្ទៃពោះដោយគ្មានការជំនុំជម្រះ។ កត្តានេះហើយដែលធ្វើឱ្យនាងសីតាលែងចង់ជួបព្រះរាមជារៀងរហូត ទោះបីជាព្រះរាមប្រើគ្រប់មធ្យោបាយក្នុងការលួងលោមយ៉ាងណាក៏ដោយ។ធ្វើឱ្យនាងសីតាអស់ជំនឿលើភក្តីភាពរបស់ខ្លួនដែលបានធ្វើពីមុនមក។

**+ដំណោះស្រាយ៖** ព្រះរាមរកវិធីសាស្ត្រមធ្យោបាយគ្រប់បែបយ៉ាងក្នុងការតាមលួងលោមនាងសីតា...។

## ៣.១.៥ វិភាគតួអង្គ

- **ព្រះរាម ៖** ព្រះរាមមានលក្ខណៈពីរយ៉ាងគឺ៖

**ក. លក្ខណៈជាអាទិទេព**

- លើកធ្នូសរបំផ្លាញក្អែកខ្មៅឈ្មោះកាកនាសូរ
- លើកធ្នូសរព្រះបាទជនកបាននាងសីតាជាមហេសី
- ដើរទៅដល់ទីណា ភាពក្រៀមក្រោះប្រែជាស្រស់បំព្រង
- មានទិព្វញ្ញាណ (ដឹងថាព្រះភិរុតតាមរកព្រះអង្គ)
- ពេលដែលព្រះរាមឈ្នះសភាវៈអាក្រក់ម្តងៗ មានទេវតាបាចផ្កាជូនពរ
- មានទិព្វញ្ញាណដឹងថាប្រើសមាសជាយក្សប្រែក្រឡា
- ពេលដែលព្រះរាមដេកក្រោមដើមស្វាយព្រះអាទិត្យមិនហ៊ានគោចរ

- ព្រះរាមមានកងចក្រនៅបាតដៃទាំងពីរ
- ព្រះរាមមើលឃើញកណ្តួលរតន៍របស់ហនុមាន ដែលគ្មានអ្នកណាអាចមើលឃើញ
- ទ្រង់ញាណដឹងថាក្រុងពាលីមិនកាន់ពាក្យសច្ចៈពីអតីតជាតិ
- គំរាមកំហែងទេវតា
- ទេវតាខ្លបខ្លាចគ្រប់គ្នា

**ខ. លក្ខណៈជាមនុស្ស**

**+ គុណសម្បត្តិ**

- គោរពពាក្យសច្ចៈមិនព្រមសោយរាជ្យជំនួសបិតា
- មានខន្តី សុខចិត្តអត់ធ្មត់មិនតបតនឹងនាងកៃកេសីជាម្តាយចុង
- សុខចិត្តលះបង់រាជសម្បត្តិទៅរស់នៅក្នុងព្រៃ១៤ឆ្នាំ
- ប្រកាន់អហិង្សាដោយអប់រំព្រះលក្ស្មណ៍កុំឱ្យខឹងនឹងម្តាយចុង

**+ គុណវិបត្តិ**

- ធ្វេសប្រហែស ដេញបាញ់ប្រើសមាសក្រឡាខ្លួនទុកនាងសីតាឱ្យយក្សឆក់យកបាន
- មានការប្រមាថ អាងខ្លួនខ្លាំងទៅសម្លុតគេឯង
- មានភាពកាចសាហាវ សម្លាប់យក្សយ៉ាងក្រពុលមុខគ្មានដឹងខុសត្រូវ
- មានការច្រណែនប្រច័ណ្ឌ ខឹងក្រុងរាពណ៍ឆក់យកនាងសីតា ប្រច័ណ្ឌនាងសីតាគូររូបក្រុងរាពណ៍
- មានការភ័យតក់ស្លុត យំសោកស្តាយនាងសីតា តក់ស្លុតឃើញប្អូនត្រូវរបួស លែងស្គាល់ទិសតំបន់ដោយហេតុការណ៍ផ្សេងៗ សាកសួរហោរាជាដរាប
- មានចិត្តកំសាក ពឹងតែកម្លាំងហនុមាន លបបាញ់ពាលីដោយមិនដឹងខ្លួន ខ្ចីអាវព្រះនារាយណ៍មកពាក់ឱ្យមហាជម្ពូខ្លបខ្លាច
- មានគំនិតចក្រពត្តិ បំបែកបំបាក់បងប្អូនគេ( ពាលីនិងសុគ្រីព ) ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន
- ជាឈ្មួញសង្គ្រាម ព្រះរាមជាមេសឹកទិញមនុស្សគំរាមកំហែងអ្នកដទៃព្រោះរឿងផ្ទាល់ខ្លួន ធ្វើសង្គ្រាមជាមួយកូនក្មេង (រាមលក្ស្មណ៍ និងជប្បលក្ស្មណ៍)
- បរាជ័យក្នុងរឿងស្នេហា

- មានចិត្តស្រាលឆាប់ឆេវឆាវ។
- **នាងសីតា**

**+ គុណសម្បត្តិ**

- រូបល្អលើសនារីត្រៃភព
- មានចិត្តស្នេហាស្មោះស្ម័គ្រជាមួយស្វាមី
- មានចរិយាល្អប្រពៃ
- គោរពអ្នកដទៃជាពិសេសអ្នកបួស
- មិនព្រមរាបការជាមួយក្រុងរាពណ៍ រង់ចាំព្រះរាម១០ខែសុខចិត្តស្លាប់
- មិនជឿផ្ដេសផ្ដាសដោយគ្មានភស្តុតា

**+ គុណវិបត្តិ**

- មានចិត្តលោភ និងស្រណោះរាជបល្ល័ង្ក
- ស្រឡាញ់បុណ្យសក្តិ
- ឆាប់ភ័យតក់ស្លុត
- មានចិត្តរឹងរូស ចង់មានស្បែកប្រើសមាស ទោះបីព្រះរាមប្រាប់ថាជាយក្សប្រែក្រឡាក៏ដោយ
- **រាមលក្ស្មណ៍ និងជប្បលក្ស្មណ៍**

**+ គុណសម្បត្តិ**

- កុមារទាំងពីរចេះអាណិតស្រឡាញ់ជួយគ្នាទៅវិញទៅមក ដូចជាពេលគេចាប់រាមលក្ស្មណ៍ ជប្បលក្ស្មណ៍បានប្រើល្បិចទៅរំដោះ
- មានសីលខ្ពស់ស្មើព្រះរាយណ៍ជាបិតា គឺហួសពីក្មេងនានាដោយវាមានអាយុត្រឹមតែ១០ឆ្នាំតែខ្លាំងក្លាអស្ចារ្យ
- ស្រឡាញ់ប្រណិប័តន៍មាតា នឹករឭកមាតាយ៉ាងខ្លាំង
- ព្យាយាមផ្សះផ្សាទំនាស់រវាងអ្នកមានគុណទាំងពីរ
- អាចចាប់ហនុមានបាន

**+ គុណវិបត្តិ**

- របិុលរប៉ូចល្មើសនឹងបម្រាមចាប់សេះរបស់ព្រះមហាក្សត្រជិះលេងទោះបីឃើញសារចងភ្ជាប់សេះក៏ដោយ
- ព្រហើនកោងកាច ពុំគោរពមនុស្សចាស់ ពុំចេះគួរសម
- ទាមទារឱ្យព្រះរាមប្រាប់ពីពង្សសន្តានជាមុន ទើបប្រាប់ជាក្រោយ
- ក្មេងក្អាង ហួសពីសមត្ថភាព ដោយខ្លួនមានតែពីរនាក់ ហើយជាកុមារតូចៗបែរជាចង់តតាំងនឹងមហាក្សត្រ ដែលមានទ័ពច្រើននិងពូកែៗ។

## ៣.១.៥ វិភាគបញ្ហាផ្សេងៗ

❖ បញ្ហាទំនាស់រវាងព្រះរាម និងនាងសីតា

→ **តើការបដិសេធរបស់នាងសីតាអំពីសំណើរនៃការលួងលោមរបស់ព្រះរាមក្នុងការដែលសុំឱ្យវិលទៅនគរវិញត្រឹមត្រូវដែរឬទេ?**

**+ព្រះនាងសីតាបដិសេធពិតជាត្រឹមត្រូវ ពីព្រោះ៖**

- បើតាមដំណើររឿងយើងអាចដឹងបានថា ព្រះរាមបានធ្វើទារុណកម្មផ្លូវចិត្ត និងផ្លូវកាយនាងសីតាជាខ្លាំង ដោយបញ្ជាឱ្យព្រះលក្ស្មណ៍យកនាងទៅសម្លាប់ដោយពុំគិតស្រណោះ ប្រពន្ធដែលមានផ្ទៃពោះក្នុងខ្លួនក៏ដោយ ហើយចំពោះផ្លូវចិត្តវិញគឺធ្វើឱ្យមានខ្លោចផ្សាជាទម្ងន់ព្រោះថាក្នុងនាមជាគូរស្នេហ៍និងគ្នាគឺវាឈឺចាប់ណាស់ដែលស្វាមីពុំមានមនោសញ្ចេតនាដាក់ខ្លួនបែបនេះ។
- បើនិយាយពីផ្លូវធម៌វិញនោះគឺព្រះរាមពិតជាខុសធ្ងន់ណាស់ដែលប្រមាថអាយុជីវិតគេដោយកំរោល ស័ក្តិសមហើយដែលនាងសីតាមិនព្រមលើកលែងទោសឱ្យ ហើយការសម្រេចចិត្តរបស់នាងដែលមិនទន់ទោរលើពាក្យសំដីក្នុងការលួងលោមរបស់ព្រះរាមដែលអង្វរឱ្យទៅព្រះនគរវិញពិតជាត្រឹមត្រូវ
- ដោយសារតែពាក្យសត្យរបស់នាងសីតាដែលសច្ចាថាមិនផ្សះផ្សារជាមួយព្រះរាមឡើយ ដូចដែលឃ្លានាងសីតាបានពោលទៅព្រះរាមថា "*កើតមកជាតិនេះមានកម្ម នៅវេទម្រាំខ្លួនក្ស័យ បុណ្យខ្ញុំនឹងមហាក្សត្រថ្លៃ សមអស់តែម្លេះហើយណា*"។

**+ព្រះនាងសីតាបដិសេធនេះគឺពុំត្រឹមត្រូវទេ ព្រោះ៖**

- ដោយផ្អែកលើមនោសញ្ចេតនារវាងប្តីនិងប្រពន្ធត្រូវតែមានការយោគយល់អធ្យាស្រ័យឱ្យគ្នាមិនត្រូវបដិសេធដាច់ខាតឡើយ

- ការធ្វើបែបនេះគឺមិនទុកមុខឱ្យព្រះស្វាមីដែលមានឋានៈជាព្រះរាជាឡើយ ដែលធ្វើឱ្យអាប់ឱនដល់ដំកិត្តិយសរបស់ព្រះអង្គ
- ការដឹងខុសហើយយើងចេះទទួលកំហុសរបស់ខ្លួនពិតជាគួរអឲ្យស្រ័យឱ្យ ដូចដែលព្រះរាមបានដឹងនៅកំហុសរបស់ខ្លួន ព្រះទាំងសុំអង្វរឱ្យនាងសីតាលើកលែងទោស ដូចក្នុងឃ្លាដើម "បែងនឹងរកស្រីឯណាឲ្យមានកិរិយាដូចពៅ ចូរប្អូនអាចអត់ទោសទៅ គិតកាលកំសត់នឹងគ្នា"។

→ **តើការដែលព្រះរាមយក រាមលក្សណ៍និងជប់លក្សណ៍ទៅនគរវិញដោយឃ្លាតពីនាងសីតាតើត្រឹមត្រូវដែរឬទេ ?**

**+ត្រឹមត្រូវ ព្រោះ៖**

- ក្នុងនាមជាបិតាចាំបាច់ត្រូវតែទទួលខុសត្រូវចំពោះកូនរបស់ខ្លួន
- ដើម្បីយកមកទូន្មានប្រដៅ
- ដើម្បីស្នងរាជពីបិតា
- តបស្នងនៅកំហុសដែលខ្លួនបានធ្វើ...

**+មិនត្រឹមត្រូវទេ ព្រោះ៖**

- ត្រូវបំបែកបំបាក់រវាងម្តាយនិងកូន
- ព្រះរាមធ្វើបែបនេះគឺដោយសារតែជាល្បិចលួងលោមបញ្ឆោតនាងសីតាតែប៉ុណ្ណោះ
- អាងរិទ្ធអំណាចធ្វើអ្វីតាមតែចិត្តដោយមិនគិតពីអ្នកណាឡើយ...។

## ៣.២ វិភាគអត្ថរូប

### ៣.២.១ វិភាគពាក្យពេចន៍

ចំពោះពាក្យពេចន៍ទាំងឡាយដែលអ្នកនិពន្ធបានប្រើក្នុងរឿងរាមកេរ្តិ៍ក្នុងភាគទី៧៩នេះអ្នកនិពន្ធបានប្រើប្រាស់ពាក្យចម្រុះ ងាយអាន ងាយយល់ ដោយការប្រើប្រាស់ភាសា មានលក្ខណៈប្រហាក់ប្រហែលនឹងភាសាសរសេរទំនើបបច្ចុប្បន្នដែរ

- ពាក្យសំស្ក្រឹតមានដូចជា៖

- សាក្សី មានន័យថា ស្មរ បន្ទាល់
- មហាក្សត្រ មានន័យថា ក្សត្រធំ ក្សត្រិយ៍ប្រសើរ

- រាស្ត្រ មានន័យថា ដែន ប្រទេស
    - ពាក្យខ្មែរមានដូចជា៖
- មន្ទិល មានន័យថា ដំណើរសៅហ្មង ការស្មោកគ្រោក
- អាក់អន់ មានន័យថា មានថ្នាំងថ្នាក់ចិត្ត, ខឹងសម្បាបន្តិចបន្តួច
- កំហឹង មានន័យថា សេចក្តីខឹង

### ៣.២.២ វិភាគឃ្លាល្បះ

ចំពោះឃ្លានៅក្នុងល្បះនៃកំណាព្យក្នុងរឿងរាមកេរ្តិ៍ខ្សែទី៧៩ តាមការសិក្សាឃើញថារាល់ឃ្លាដំបូង(ឃ្លាទី១)ក្នុង វគ្គនីមួយៗនៃកំណាព្យអ្នកនិពន្ធបានប្រើប្រាស់ ឃ្លាភាគច្រើនគឺ ឃ្លា "កាលអើយកាលនោះ" ព្រមទាំងការប្រើប្រាស់ ចុងចួន ផ្ទួន និងរណ្តំ យ៉ាងពីរោះ។

### ៣.២.៣ វិភាគជើងកាព្យ

នៅក្នុងរឿងរាមកេរ្តិ៍ខ្សែទី៧៩យើង នេះឃើញថាការអ្នកនិពន្ធបានប្រើវិធីតែងនិពន្ធដោយប្រើ កំណាព្យ "បទរាយ, និយាយ បទរាយ, ភ្លេង បទរាយ, ស្មើ បទរាយ, ដើត បទរាយ, ភ្លេងឆា បទរាយ, ឲត បទពិលាប, ឲត បទរាយ, ស្មើ បទពិលាប, ក្រៅណក បទរាយ, ដើត បទខឹនម៉ា, ភ្លើង បទរាយ, ឱត បទរាយ ។

## ៣.៣ វិភាគអត្ថរស

### ៣.៣.១ វិភាគអច្ឆរិយរស

ដំណើររឿងរាមកេរ្តិ៍ខ្មែរក្នុងខ្សែទី៧៩ គឺភាពអច្ឆរិយរសតាំងពីដើមរហូតដល់ចប់។ កវីបានលើកយកនូវភាពអស្ចារ្យរបស់តួអង្គផ្សេងៗមកបង្ហាញ ដូចជានាងសីតាលុយភ្លើង ដើម។

### ៣.៣.២ វិភាគកុសលរស

ដំណើររឿងបានអប់រំអ្នកអានដូចជា៖

- មុនធ្វើអ្វីមួយត្រូវចេះគិតពិចារណា
- ឱ្យចេះស្គាល់នៅកំហុសខ្លួន និងចេះទទួលស្គាល់នូវកំហុសរបស់ខ្លួន
- ឱ្យតម្លៃលើពាក្យសត្យ
- អប់រំកូនត្រូវចេះស្រឡាញ់អ្នកមានគុណ...

### ៣.៣.៣ វិភាគទារុណរស

នៅក្នុងដំណើររឿងអ្នកនិពន្ធបានបង្ហាញពីការព្រាត់ប្រាស់គ្នារវាងកូន និងម្ដាយ ដែលមានភាពនឹករលឹកគ្នាជាពុនពេកនៅពេលដែលព្រះរាមបានយករាមល្បណ៍ និងជប់លក្សណ៍ទៅនគរ

## IV ជំពូកទី៤៖ លក្ខណៈវិជ្ជមាន អវិជ្ជមាន (ឥទ្ធិពល តម្លៃសង្គម ការអប់រំ...)

### ៤.១ លក្ខណៈវិជ្ជមាន

នៅក្នុងខ្សែទី៧៩នៃរឿងរាមកេរ្តិ៍ខ្មែរយើងបានផ្ដល់នូវ៖

- គ្រួសារ៖អប់រំទៅលើទំនាក់ទំនងរវាងប្ដីប្រពន្ធត្រូវមានចិត្តត្រាប្រណៃគ្នានឹងគ្នា ចេះយល់ចិត្តគ្នា នឹងមានភាពស្មោះត្រង់នឹងគ្នា ព្រមទាំងចេះអត់ឱនឱ្យគ្នា មិនត្រឹមតែប៉ុណ្ណោះផ្ដល់នូវទំនួលខុសត្រូវទៅលើកូន កូនចេះដឹងគុណគោរពឪពុកម្ដាយ
- សង្គម៖ ឥទ្ធិពលទៅលើការឱ្យតម្លៃស្ត្រី ដូចដែលព្រះរាមបានតាមលួងលោមមានសីតាជាតឹកតាងស្រាប់ លើសពីនេះក៏ឱ្យតម្លៃទៅលើពាក្យសត្យ ដែលជាផ្នត់គំនិតរបស់ខ្មែរយើងពីបុរាណ

### ៤.២ លក្ខណៈអវិជ្ជមាន

នៅក្នុងខ្សែទី៧៩នៃរឿងរាមកេរ្តិ៍ខ្មែរយើងបានផ្ដល់នូវ៖

- ការដែលនាងសីតាមិនព្រមផ្សះផ្សាជាមួយព្រះរាមគឺជាអំពីមួយដែលដែលអាចនឹងជះឥទ្ធិពលដល់មនុស្សនៅក្នុងសង្គមឱ្យយកគំរូដែលមិនមានការអាធ្យាស្រ័យដល់អ្នកដែលដឹងខុសហើយចេះទទួលខុសត្រូវ
- ធ្វើឱ្យមនុស្សប្រកាន់តែចិត្តខ្លួន

## V ជំពូកទី៥៖ សន្និដ្ឋាន

ជារួមក្រោយពីបានធ្វើការវិភាគលើបញ្ហា និងសិក្សាលើអំណះអំណាងរួចមកយើងឃើញថារឿងរាមកេរ្តិ៍ខ្មែរក្នុងខ្សែទី៧៩នេះមានបង្កប់នៅអត្ថន័យជាច្រើន ដែលបង្ហាញនៅឧត្តមគតិល្អដល់មនុស្សក្នុងសង្គម ព្រមទាំងធ្វើជាទឡ្ហីករណ៍ដល់មនុស្សទុកធ្វើការគិតពិចារណា។

### ឯកសារពិគ្រោះ

ដកស្រង់ចេញពី( *សៀវភៅរាមកេរ្តិ៍ខ្សែទី៧៩ , ឯកសារអក្សរសិល្ប៍សម័យអង្គររបស់លោកគ្រូ ឃិន យ៉ន់ និង សៀវភៅសិក្សាអត្ថបទអក្សរសិល្ប៍ សម្រាប់មធ្យមសិក្សាទុតិយភូមិ "នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ២០១៩"*)។